# ទំនាក់ទំនងយោធា និងសន្តិសុខរវាងខ្មែរ និងចិន
# ក្នុងសម័យចក្រភពខ្មែរពីសតវត្សរ៍ទី៣ ដល់ សតវត្សរ៍ទី១៥

បណ្ឌិត ជិន សុជាតិ
មន្ត្រីស្រាវជ្រាវវិទ្យាស្ថានសិក្សាចិន នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១. ទំនាក់ទំនងសម័យមុនអង្គរ(សតវត្សរ៍ទី១ ដល់សតវត្សរ៍ទី៩)

សង្គមខ្មែរបានចាប់ផ្តើមយកសាសនាហិណ្ឌូ មកគ្រប់គ្រងរដ្ឋតាំងពីដើមសម័យហ្វូណាន ដោយសារព្រាហ្មណ៍ឈ្មោះ ហ៊ុន ទៀន(ឈ្មោះតាមឯកសារចិន) ដែលបានរៀបអភិសេកជាមួយព្រះនាងលីវ យី(ឈ្មោះតាមឯកសារចិន) ដែលជាក្សត្រគ្រប់គ្រងទឹកដីនៅភាគខាងត្បូងតំបន់អាស៊ីអគ្នេយ៍ដីគោក តាំងពីប្រហែលពាក់កណ្តាលសតវត្សរ៍ទី១ នៃគ.ស.។ តាមគោលការណ៍រដ្ឋបែបសាសនាហិណ្ឌូ ត្រូវមានគោលការណ៍ ៧ យ៉ាង គឺ ទី១ អ្នកដឹកនាំរដ្ឋ ទី២ ប្រជាជន ទី៣ ទឹកដី ទី៤ បន្ទាយ ឬរាជវាំង ទី៥ កងទ័ព ទី៦ រាជឃ្លាំង ឬរតនាគារ និងទី៧ សម្ព័ន្ធមិត្ត[1] ។

តាមរយៈគោលការណ៍ខាងលើនេះ គោលការណ៍ទី៧ រដ្ឋបែបហិណ្ឌូសាសនានិយម គឺត្រូវមានសម្ព័ន្ធមិត្ត គឺតាមគោលការណ៍នេះហើយ ដែលរាជាណាចក្រខ្មែរសម័យហ្វូណានបានចាប់ផ្តើមមានទំនាក់ទំនងជាមួយចក្រភពផ្សេងៗ ក៏ដូចជាប្រទេសជិតខាង ដើម្បីស្វែងរកដៃគូសម្ព័ន្ធមិត្ត។ សម្ព័ន្ធមិត្តធំជាងគេរបស់ហ្វូណាន គឺចិន។ ការចងសម្ព័ន្ធមិត្ត ជាទូទៅវាជាទំនាក់ទំនងដើម្បីស្វែងរកផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកដែលរួមមានៈ ផលប្រយោជន៍នយោបាយ សន្តិសុខ និងសុវត្ថិភាព ផលប្រយោជន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌ជាដើម។ យ៉ាងណាក៏ដោយអត្ថបទយើងនេះគឺផ្តោតតែលើទំនាក់ទំនងនយោបាយផ្នែកយោធា និងសន្តិសុខតំបន់ប៉ុណ្ណោះ។

បើពិនិត្យលើភូមិសាស្ត្រនយោបាយនៅសម័យមុនអង្គរ យើងឃើញថា នគរណានចាវ(nanzhao) និងនគរដាយវៀត(បច្ចុប្បន្នវៀតណាម)បានបង្កើតចលនាផ្តាច់ខ្លួនពីចិនក្នុងរាជវង្សថាង(Tang dynasty)។ ដោយសារហេតុផលនេះ ចិនត្រូវការសម្ព័ន្ធមិត្តចាម និងខ្មែរដើម្បីប្រឆាំងនឹងដាយវៀត ចំណែកនគរខ្មែរត្រូវការសម្ព័ន្ធមិត្តចិន ដើម្បីទប់ទល់នឹងឥទ្ធិពលដាយវៀតផងដែរ។

---

[1] The Idea of a Hindu State (Rashtra): Cultural Aspects in the Revivalist Movement in Contemporary India Santosh C. Saha Indian Journal of Asian Affairs Vol. 14, No. 1/2 (JUNE & DECEMBER 2001),



ប្រភព ៖ https://alchetron.com/Nanzhao

ក្នុងសម័យហ្វូណាន គណៈទូតចិនទី១ គឺលោកកាង តៃ (Kang Tai) និង ជូយីង (Zhou Ying) បានមកដល់នគរខ្មែរនៅរវាងឆ្នាំ២២៥នៃគ.ស. [2] ។ ចំណែករាជទូតដំបូងរបស់ហ្វូណាន រួមដំណើរជាមួយអ្នកលេងភ្លេងបានទៅភ្ជាប់ទំនាក់ទំនងជាមួយចក្រភពចិន ដោយមាននាំសួយសារអាករមួយចំនួនទៅជាមួយជាលើកដំបូង នាឆ្នាំ ២៤៣នៃគ.ស.។ ទំនៀមទម្លាប់ការទូត ដើម្បីចងសម្ព័ន្ធភាពគ្នាជាមួយនគរចិនត្រូវបានធ្វើជាបន្តបន្ទាប់ គឺតាំងពីសម័យហ្វូណាន សម័យចេនឡា សម័យអង្គរ និងរហូតមកដល់សម័យក្រោយអង្គរថែមទៀត។

នៅឆ្នាំ៧៥០ រាជទូតនគរចេនឡាគោកឈ្មោះ វេនតាន ទៅដល់ស្រុកចិន បន្ទាប់មកដឹកនាំទ័ពវាយនគរណានឆាវ ដែលចង់ប្រកាសឯករាជ្យពីចិន ។ បន្ទាប់ពីការធ្វើសង្គ្រាម វេនតាន បានឡើងកាន់អំណាចនៅនគរចេនឡាគោក[3]។ ចលនានៃការទាមទារឯករាជ្យរបស់ពួកជាយវៀតពីនគរចិនក៏បានចាប់ផ្ដើមមានឡើងផងដែរ។ ជាទូទៅរដ្ឋនៅភាគខាងត្បូងចិនដែលមានបំណងចង់បានឯករាជ្យ មានភូមិសាស្ត្រជាតំបន់ភ្នំដែលធ្វើឱ្យយោធាចិនមិនអាចងាយនឹងវាយយកឈ្នះបាន ព្រោះពួកគេមានជំនាញតែខាងទ័ពសេះ។ ឆ្នាំ៧៧១ យោងទៅតាមកំណត់ត្រារបស់ចិន"បេសកជននៃចេនឡាជីគោក" ឈ្មោះ ភូមី បានទៅដល់ប្រទេសចិនជាមួយភរិយារបស់គាត់ និង បានថ្វាយសត្វដំរីដែលបានបង្ហាត់រួចហើយចំនួន១១ក្បាល[4]។ តាមការយល់ឃើញទំនាក់ទំនងនេះទំនងជាការសាកល្បងបញ្ជូនទ័ពដំរីនៃនគរចេនឡាក្នុងការចូលរួមជាមួយទ័ពចិនដើម្បីចូលរួមក្នុងសង្គ្រាមតាមតំបន់ព្រៃភ្នំ។

## ២. ទំនាក់ទំនងសម័យអង្គរ(សតវត្សរ៍ទី៩ ដល់សតវត្សរ៍ទី១៥)

បើពិនិត្យលើភូមិសាស្ត្រនយោបាយនៅក្នុងដំណាក់កាលនេះ យើងឃើញថា នគរដាយវៀត នគរខ្មែរបានចាប់ផ្ដើមមានឥទ្ធិពលក្នុងតំបន់ ហើយនគរដែលរងសម្ពាធ និងការវាតទីពីនគរជិតខាងគឺ រដ្ឋមន និងរដ្ឋចម្ប៉ា ដោយហេតុនេះហើយទើបយើងមើលឃើញថា រដ្ឋចម្ប៉ាតែងស្វែងរកមធ្យោបាយទប់ទល់ ឬវាយប្រហារនគរខ្មែរ ឬពេលខ្លះ

---

[2] Member of History Channel.com, *Chronology of Cambodia*, 2008 p. 5.

[3] អាដេម៉ាឡឺក្លែ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់ពីស.វទី១រហូតមក ២០០៥, ទំព័រ៨។

[4] Member of History Channel.com, op. cit., p. 6.

នគរចម្ប៉ាត្រូវស្វែងរកសម្ព័ន្ធភាពជាមួយដាយវៀតដើម្បីទប់ទល់នគរខ្មែរ។ ចំណែកនគរខ្មែរក៏ត្រូវការសម្ព័ន្ធភាពជាមួយនគរចិនដើម្បីទប់ទល់នឹងដាយវៀត ក៏ដូចជាចម្ប៉ាផងដែរ។

ចាប់ពីចុងសម័យចេនឡា ពួកជ្វាដែលនៅតំបន់ភាគខាងត្បូងនៃនគរចម្ប៉ា បានចូលវាយលុក និងគ្រប់គ្រងនគរខ្មែរអស់មួយរយៈពេល។ ក្រោយមកព្រះបាទជ័យវរ្ម័នទី២ បានវាយបកវិញនៅឆ្នាំ៨០០ និងបានប្រកាសឯករាជ្យនាឆ្នាំ៨០២។ នៅឆ្នាំ៨០៩ ពួកជ្វាបានមកធ្វើការវាយប្រហារចក្រភពអង្គរជាថ្មីទៀត តែមិនបានទទួលជ័យជំនះនោះទេ។ ចាប់ពីពេលនោះមកវិបត្តិរវាងខ្មែរ និងចាម ក៏ចេះតែបន្តកើតមានជាលំដាប់ [5] ។

នៅក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ ព្រះអង្គបានបន្តចងសម្ព័ន្ធភាពជាមួយចក្រភពចិននិងបានដាក់សម្ពាធលើពួកចាមឱ្យរួមគ្នាប្រឆាំងការរីករាលដាលនៃអំណាចរបស់ពួកដាយវៀត ប៉ុន្តែមិនទទួលបានជោគជ័យឡើយ។ មិនត្រឹមតែប៉ុណ្ណោះពួកចាមនៅនគរចម្ប៉ាបានរួមគ្នាជាមួយដាយវៀតប្រឆាំងនឹងព្រះបាទសូរ្យវរ្ម័នទី២ថែមទៀត ជាហេតុធ្វើឱ្យអ្នកដឹកនាំខ្មែររូបនេះបានវាយនគរចម្ប៉ាជាថ្មីចាប់ពីឆ្នាំ១១៤៥។ ជម្លោះនេះបានធ្វើឱ្យពួកចាមនៃនគរចម្ប៉ាបានវាយបកចូលទីក្រុងអង្គរនាឆ្នាំ១១៧៧ និងបានគ្រប់គ្រងក្រុងអង្គររហូតដល់ឆ្នាំ១១៨១ គឺពេលដែលមានការវាយបកពីសំណាក់ព្រះបាទជ័យវរ្ម័នទី៧ [6]។



ប្រភព ៖ អាជ្ញាធរជាតិអប្សរា

សង្គ្រាមខ្មែរ និងចាម ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ បានបន្សល់នូវរូបភាពជាច្រើននៅលើចម្លាក់នៃប្រាសាទបាយ័ន ដែលក្នុងនោះអ្វីដែលគួរឱ្យចាប់អារម្មណ៍គឺគេឃើញមានវត្តមានទាហានចិននៅក្នុងជួរកងទ័ពខ្មែរ និងក៏មានវត្តមាននៃសព្វាវុធស្នាយន្តរបស់ចិនក្នុងសង្គ្រាមខ្មែរ និងចាមនេះផងដែរ។

---

[5] អាដេម៉ាឡឺក្លែ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដ.ឯ.ម. ទំព័រ ១០។

[6] http://www.khmer-kulturzentrum.ch/History/Lapidaire/Lapid12.html

រូបចម្លាក់ទាហានចិន និងស្នាយន្តនៅប្រាសាទបាយ័ន្ត



ប្រភព៖ https://www.tnaot.com/km/m/detail/article/9444661

ករណីរូបចម្លាក់ទាហានចិនដែលមានវត្តមានក្នុងជួរកងទ័ពខ្មែរសម័យសង្គ្រាមចាម និងខ្មែរនេះវាបន្សល់ទុកនូវចម្ងល់ជាច្រើនថា តើទាហានទាំងនោះពិតជាទាហានចិនមែនឬ និងបើជាទាហានសំអាងលើអ្វី? តើទាហាចិនទាំងនេះជាអ្នករស់នៅក្នុងសង្គមខ្មែរ ឬជាក្រុមកងទ័ពដែលមកពីនគរចិនហើយលើកមកជួយកងទ័ពខ្មែរ? ឬរបៀបជាទាហានស៊ីឈ្នួល?

តាមរយៈទំនាក់ទំនងការទូតរវាងខ្មែរ និងចិនក្នុងរជ្ជកាលព្រះបាទសូរ្យវរ្ម័នទី២ និងបន្តមករជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ បើយើងប្រៀបធៀបទៅនឹងសម័យកាលនៃសង្គ្រាមចាមនិងខ្មែរ នេះគឺត្រូវគ្នានឹងសម័យកាលសន្តតិវង្សសុង Song Dynasty របស់ប្រទេសចិនដែលមានទឹកដីនៅក្បែរនឹងចក្រភពអង្គរ។

យើងជឿថា សង្គ្រាមរវាងនគរជើង និងសុង ដែលបានកើតឡើងនៅរវាងឆ្នាំ១១៦១ ដែលជាហេតុនាំឱ្យមានលំហូរជនជាតិចិនទៅកាន់តំបន់ផ្សេងៗជាពិសេសក្នុងចក្រភពអង្គរ។ តាមរយៈការសិក្សានានានៅសម័យអង្គរយើងមើលឃើញថា ជនជាតិចិនទំនងជាបានតាំងទីលំនៅក្នុងប្រទេសកម្ពុជាតាំងពីសម័យអង្គរមកម្លេះ ព្រោះគេបានឃើញជនជាតិចិននៅលើសមរភូមិប្រយុទ្ធ នៅក្នុងទីផ្សារ នៅក្នុងវង់ល្បែងជល់មាន់ និងសកម្មភាពផ្សេងៗទៀតក្នុងសង្គមខ្មែរ។

ចម្លាក់បាយ័នបង្ហាញអំពីវត្តមានជនជាតិចិនក្នុងជីវភាពខ្មែរ



ប្រភព ៖ តឹក មេង, ជិន សុជាតិ, *ប្រវត្តិសេដ្ឋកិច្ចប្រទេសកម្ពុជា*, ភ្នំពេញ ២០១៧

នៅក្នុងជីវភាពប្រជាជនខ្មែរគេឃើញមានការពេញនិយមក្នុងការប្រើប្រាស់ទំនិញជាច្រើនពីស្រុកចិន ដូចជា សំណាញ់ ក្រដាស ឆ័ត្រ ក្រាស ម្ជុល និងឆ្នាំងដែកជាដើម។ ក្រៅពីនេះគេឃើញមានការផលិតក្បឿងពីដីដុតដែលផលិតតាមម៉ូតក្បឿងសេរ៉ាមិចចិនផងដែរ ។

ក្បឿងសេរ៉ាមិចចិនដែលគេរកឃើញក្នុងតំបន់អង្គរ និងក្បឿងដីដុតសម័យអង្គរ




ប្រភព ៖ តឹក មេង, ជិន សុជាតិ, ***ប្រវត្តិសេដ្ឋកិច្ចប្រទេសកម្ពុជា***, ភ្នំពេញ ២០១៧។

ដោយឡែក វត្តមានទ័ពសេះក្នុងសម័យអង្គរយើងក៏មានជំនឿថា ខ្មែរមានទំនាក់ទំនងជាមួយជនជាតិចិនមិនតិចនោះទេ យើងអាចមានសំណួរថា កងទ័ពសេះទាំងនេះមានការចូលរួមបង្វឹកទាហានខ្មែរពីសំណាក់ក្រុមទាហានចិនណាមួយដែរឬទេ?

ចម្លាក់ទ័ពលើប្រាសាទបាយ័ន និងប្រាសាទអង្គរ




ប្រភព ៖ អាជ្ញាធរជាតិអប្សរា

នៅក្នុងការធ្វើសង្គ្រាមរវាងខ្មែរ និងចាមនាសម័យព្រះបាទជ័យវរ្ម័នទី៧នេះ គេក៏ឃើញមេទ័ពចិនមួយចំនួនរៀនជិះដំរីធ្វើសង្គ្រាមតាមខ្មែរដែរ ព្រោះអាចជាមេរៀនក្នុងការធ្វើសង្គ្រាមប្រឆាំងនឹងដាយវៀតដែលមានភូមិសាស្ត្រជាព្រៃភ្នំ។



ប្រភព ៖ https://grandnewsasia.com/detail/25293/

គួរបញ្ជាក់ថា សង្គ្រាមខ្មែរចាម គឺបានកើតឡើងមុនពេលដែលចក្រភពម៉ុងហ្គោលីចូលឈ្លានពានអាណាចក្រសៀខាងលិច អាណាចក្រជីង និងអាណាចក្រសុងរបស់ប្រទេសចិន ហេតុនេះ វត្តមានកងទ័ពចិននៅលើចម្លាក់បាយ័នគឺអាចជាក្រុមជនជាតិចិនដែលបានតាំងទីលំនៅក្នុងតំបន់ណាមួយនៃសម័យអង្គរ ឬជាក្រុមកងទ័ពដែលនគរចិនបញ្ជូនមកដើម្បីជួយបង្វឹកទាហានសេះខ្មែរ ក្នុងការប្រយុទ្ធប្រឆាំងនឹងអំណាចដាយវៀត រួមទាំងនគរចម្ប៉ាដែលមានសម្ព័ន្ធភាពជាមួយនឹងនគរដាយវៀត។ ព្រោះទំនៀមនៃការជួយគ្នារវាងកងទ័ពខ្មែរ និងចិន បានកើតមានឡើងតាំងពីរជ្ជកាលព្រះបាទហស៌វរ្ម័នទី៣ គឺនៅឆ្នាំ១០៧៣ ដែលបានរួមគ្នាប្រយុទ្ធនឹងដាយវៀត[7]។

ជារួម យើងមើលឃើញថា ទំនាក់ទំនង រវាងខ្មែរចាមគឺបានកើតមានតាំងពីសម័យចក្រភពខ្មែរ ដែលមានសម្ព័ន្ធភាពដើម្បីជួយគ្នាទៅវិញទៅមកលើការងារយោធា និងសន្តិសុខតំបន់ ដែលនេះបានបង្ហាញថា ចំណងមិត្តភាពខ្មែរ និងចិនមិនមែនទើបកើតក្នុងក្នុងពេលថ្មីៗនេះទេ ពោគឺចាប់កើតមានតាំងពីសម័យកកើតនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជាមកម្លេះ ។ ទំនាក់ទំនងកម្ពុជា និងចិនមិនមែនតែលើវិស័យយោធា និងសន្តិសុខប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានទំនាក់ទំនងដ៏យូរអង្វែងទាក់ទងនឹងសេដ្ឋកិច្ច ពាណិជ្ជកម្ម សង្គម និងវប្បធម៌ផងដែរ ហើយយើងសង្ឃឹមថា ទំនាក់ទំនងនេះនឹងបន្តទៅមុខសម្រាប់ការរីកចម្រើននៃប្រទេសទាំងពីរយូរអង្វែងទៅមុខទៀត។

[7] អាដេម៉ាឡឺក្លែ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដ.ឯ.ម. ទំព័រ ១០៣។